ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែមីនា ឆ្នាំ២០១៧

នៅក្នុងខែមីនា ឆ្នាំ២០១៧នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា បានៈ

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក និងសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ព្រឹទ្ធសភា ចំនួន០១លើក

-អញ្ជើញជូនព្រះរាជដំណើររបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** យាងចេញពីមាតុប្រទេសទៅកាន់សាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អនុញ្ញាតឲ្យ**លោកជំទាវ អ៊ឹង កន្ថាផាវី** និងគណៈប្រតិភូនារី ចំនួន១៦៥រូប ចូលជួបសម្តែងការគួរសមក្នុងឱកាសអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ **ស្ត្រីដើម្បីសន្តិភាព និងវឌ្ឍនភាព**

-អញ្ជើញជាអធិបតីក្នុងពិធីស្រោចស្រពសុគន្ធវារី ប្រគេនព្រះមេគុណខេត្តកំពង់ស្ពឺ និងមន្ត្រីសង្ឃ ក្រុង ស្រុកទាំង៨ នៃខេត្តកំពង់ស្ពឺ

-អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកតា និងលោកយាយ នៅសង្កាត់អូឬស្សី ខណ្ឌ៧មករា និងភូមិតាភេម ភូមិត្រពាំងក្នុងសង្កាត់កំបូល ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខ័ន្ធ ពិធីបូជាសព ពិធីរាបបាត្របុណ្យខួប៧ថ្ងៃ ជាមួយនិង១០០ថ្ងៃ **សម្តេចវិបុលបញ្ញាសុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅរាជធានីភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើព្រះរាជក្រមចំនួន០១ច្បាប់ ព្រះរាជក្រឹត្យចំនួន៣៩ច្បាប់ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៣៦ច្បាប់ ទទួលសំណើក្រុមប្រឹក្សាធម្មនុញ្ញ និងពីរាជរដ្ឋាភិបាល៣៦ច្បាប់ ព្រមទាំងឯកសារផ្សេងៗចំនួន០២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២២ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា ប្លាន** :

-ទទួលភារកិច្ចប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ចំនួន០១លើក

-អនុញ្ញាតឲ្យ**ឯកឧត្តម ហ្វីលីព កូរ៉ាដ** (Philippe Courard) ប្រធានសភាសហព័ន្ធវ៉ាល់ឡូនីប្រ៊ុយសែល ជួបសម្តែងការគួរសម ពិភាក្សាការងារ និងចុះហត្ថលេខាលើអនុស្សារណៈយោគយល់រវាងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយសភាសហព័ន្ធវ៉ាល់ឡូនីប្រ៊ុយសែល

-អនុញ្ញាតឲ្យ**ឯកឧត្តម វ៉ាំងសង់ អេប្លេ** (Vincent Eble) សមាជិកព្រឹទ្ធសភា និងជាប្រធានក្រុមមិត្តភាពបារាំង-កម្ពុជា ចូលជួបសវនាការ និងសម្តែងការគួរសម

-អញ្ជើញជាអធិបតីភាពក្នុងពិធីជប់លៀងជាកិត្តិយសជូនគណៈប្រតិភូសភាសហព័ន្ធវ៉ាល់ឡូនីប្រ៊ុយសែលនៃប្រទេសប៊ែលហ្ស៊ិក ដឹកនាំដោយ **ឯកឧត្តម ហ្វីលីព កូរ៉ាដ** (Philippe Courard) ប្រធានសភាសហព័ន្ធវ៉ាល់ឡូនីប្រ៊ុយសែល នៅសណ្ឋាគារអ៊ិនធើខុនទីណង់តាល់ភ្នំពេញ

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខ័ន្ធ និងពិធីបូជាសព**សម្តេចវិបុលបញ្ញា សុខ អាន** នៅមុខវត្តបុទុមវតី

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន០៧ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៤៩ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ចំនួន០១លើក

-អញ្ជើញជាអធិបតី និងថ្លៃងសុន្ទរកថាបើកសិក្ខាសាលាស្តីពី បុណ្យទិវាកាសាបារាំង

-អនុញ្ញាតឲ្យក្រុមអ្នកវិនិយោគមកពីសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

-អញ្ជើញទៅពិនិត្យការដ្ឋានសាងសង់សាលារៀន និងជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ នៅអនុវិទ្យាល័យព្រះពុទ្ធ ឃុំព្រះពុទ្ធ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

-អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងសួរសុខទុក្ខពីជីវភាព និងការលក់ដូររបស់អាជីវករ នៅផ្សារកសិករ

-អញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ និងប្រជាពលរដ្ឋនៅសង្កាត់កំពង់សំណាញ់ សង្កាត់តាខ្មៅ ស្រុកអង្គស្នួល ស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញទៅសួរសុខទុក្ខ**សម្តេចវិបុលបញ្ញា សុខ អាន** ដែលសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញចូលរួមគោរពវិញ្ញាណក្ខ័ន្ធ និងពិធីបូជាសព**សម្តេចវិបុលបញ្ញា សុខ អាន** នៅមុខវត្តបុទុមវតី

-អញ្ជើញជាអធិបតីលៀងសាយភោជន៍ ជូនគណៈប្រតិភូសាធារណរដ្ឋឥណ្ឌូនេស៊ី ដឹកនាំដោយឯកឧត្តម Jusuf Kulla អនុប្រធានាធិបតី ដែលបានអញ្ជើញមកចូលរួមគោរពវិញ្ញាណក្ខ័ន្ធសព **សម្តេចវិបុលបញ្ញា សុខ អាន** នៅភោជនីយដ្ឋានតូប៉ាស់

-អញ្ជើញជាអធិបតីក្នុងពិធីជប់លៀងជូនគណៈប្រតិភូព្រឹទ្ធសភាបារាំងនៅសណ្ឋាគារប្រេស៊ីដង់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩១ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៦២ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក:**

១.ពិនិត្យ និងសម្រេចលើសំណើរបស់សមាជិកព្រឹទ្ធសភាស្នើសុំកោះប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ

២.ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការទី៦ព្រឹទ្ធសភា សុំដាក់សេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ

៣.ពិនិត្យ និងសម្រេចលើសេចក្តីព្រាងរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៩ និងលើកទី១០ ព្រឹទ្ធសភា នីតិកាលទី៣

៤.កំណត់កាលបរិច្ឆេទ និងរបៀបវារៈប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣ ។

**៣.កិច្ចប្រជុំវិសាមញ្ញចំនួន០១លើក**

១.ពិនិត្យ និងឲ្យយោបល់លើសេចក្តីស្នើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពី គណបក្សនយោបាយ ។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែមីនានេះ សមាជិក-សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

**៤.១. មុខងារនីតិកម្ម**

-គណៈកម្មការជំនាញបានប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីស្នើច្បាប់ចំនួន០១ ។

**៤.២. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះសិក្សាស្រាវជ្រាវពីកត្តាសំខាន់ៗ ដែលជំរុញឲ្យមានការអភិវឌ្ឍរបស់ប្រជាពលរដ្ឋ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលពាក់ព័ន្ធនឹងវិស័យដែលជាសមត្ថកិច្ច នៅខេត្តពោធិ៍សាត់ ខេត្តបន្ទាយមានជ័យ ខេត្តប៉ៃលិន និងខេត្តបាត់ដំបង

-អញ្ជើញចុះបេសកកម្មទៅខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ ដើម្បីសិក្សាឈ្វេងយល់អំពីៈ

១.របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នៅថ្នាក់ឃុំ សង្កាត់

២.របៀបដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ផ្តោតលើមណ្ឌលសេវាកម្មយុត្តិធម៌ស្រុក ក្រុង របៀបដោះស្រាយទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដីស្រុក ក្រុង និងការដោះស្រាយវិវាទផ្សេងៗ ព្រមទាំងការចូលរួមអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ព្រមទាំងការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ

៣.ការអនុវត្តច្បាប់ និងរបៀបដោះស្រាយទំនាស់ដែលថ្នាក់ស្រុក ក្រុងបញ្ជូនមកថ្នាក់ខេត្ត ការងារផ្សព្វផ្សាយច្បាប់ និងការងារនីតិកម្ម ព្រមទាំងការចូលរួមអនុវត្តក្រម

ព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងការទប់ស្កាត់បទល្មើសព្រហ្មទណ្ឌ

៤.សកម្មភាពការងាររបស់នគរបាលយុត្តិធម៌ ចំពោះការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងការពិនិត្យ និងទប់ស្កាត់ បង្ការបង្រ្កាបបទល្មើសព្រហ្មទណ្ឌ នៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិត្រពាំងស្រែក្នុងខេត្តក្រចេះ និងច្រកទ្វារត្រពាំងផ្លុង ក្នុងខេត្តត្បូងឃ្មុំ

៥.ការអនុវត្តក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តក្រចេះ និងខេត្តត្បូងឃ្មុំ និងសកម្មភាពការងាររបស់មន្រ្តីនគរបាលយុត្តិធម៌ចំពោះការអនុវត្តក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ក្នុងកិច្ចការងារជាមួយសាលាដំបូងខេត្ត និងអយ្យការអមសាលាដំបូងខេត្តទាំងពីរ ។

**៤.៣. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៨ករណី ផ្ញើលិខិតអន្តរាគមន៍ទៅស្ថាប័នមានសមត្ថកិច្ចដោះស្រាយចំនួន១៥ករណី ព្រមទាំងបានជូនដំណឹងទៅម្ចាស់បណ្តឹងអំពីចំណាត់ការចំនួន១៥នាក់

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បើកកិច្ចប្រជុំដើម្បីពិនិត្យ និងសម្រេចលើគម្រោងចុះឈ្វេងយល់អំពីវឌ្ឍនភាពការងារ បន្ទាប់ពីបានរៀបចំវេទិកាថ្នាក់ស្រុកស្តីពីការលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងភូមិឃុំមានសុវត្ថិភាព នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញជួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរឃុំស្រងែ ឃុំព្រៃឈរ ឃុំល្វា ឃុំសូរ្យសែន ឃុំសំពោង ឃុំតុងរ៉ុង និងឃុំខ្វិតធំ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ បើកកិច្ចប្រជុំបូកសរុបលទ្ធផលនៃការចុះតាមដានទាំងប្រាំខេត្ត ក្រោយវេទិកាបូកសរុបថ្នាក់ភូមិភាគកន្លងមក និងលើកទិសដៅការងារបន្តសម្រាប់ឆ្នាំ២០១៧

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បើកកិច្ចប្រជុំដើម្បីពិភាក្សាលើនីតិកាលវិធីកិច្ចប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៣

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ស្តីពីការត្រៀមរៀបចំគោលការណ៍ចុះតាមបណ្តាស្រុក ដើម្បីចែករំលែក និងផ្តល់ព័ត៌មានដល់ឃុំ អំពីនីតិវិធីនៃការចុះឈ្មោះបោះឆ្នោតក្រុមប្រឹក្សាសង្កាត់

-អញ្ជើញចូលរួមសិក្ខាសាលារួមគ្នាលើកទី៧ស្តីពី បទពិសោធន៍ក្នុងការតាមដានត្រួតពិនិត្យថវិកាជាតិ និងការវិនិយោគសាធារណៈ រវាងគណៈកម្មការទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងសវនកម្មរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា រដ្ឋសភាឡាវ រដ្ឋសភាមីយ៉ាន់ម៉ា និងរដ្ឋសភាវៀតណាម

-អញ្ជើញទទួលបដិសណ្ឋារកិច្ច និងអមដំណើរ ក្នុងឱកាសគណៈប្រតិភូព្រឹទ្ធសភាបារាំងនៃសាធារណរដ្ឋបារាំង អញ្ជើញមកបំពេញទស្សនកិច្ច នៅខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តពោធិ៍សាត់

-អញ្ជើញចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ សង្កាត់ខេត្តបន្ទាយជ័យ ស្តីអំពីការជំរុញស្ត្រីចូលរួមជ្រើសរើសអ្នកដឹកនាំឃុំ សង្កាត់

-អញ្ជើញចូលរួមសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧ លើប្រធានបទ ការឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃសម្រាប់ឧស្សាហូបនីយកម្ម កំណើន និងការអភិវឌ្ឍក្នុងសម័យឌីជីតាល់

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ទិវាភាសាបារាំងនៅកម្ពុជា ភាសាបារាំងក្នុងវិស័យព័ត៌មានវិទ្យា និងភាសាបារាំងក្នុងវិស័យសេដ្ឋកិច្ច

-អញ្ជើញចូលរួមជំនួបពិភាក្សាការងារជាមួយប្រតិភូនៃសភាសហព័ន្ធវ៉ាល់ឡូនីព្រុយសែល (PFWB) ដឹកនាំដោយ ឯកឧត្តម **ហ្វីលីព កូរ៉ាដ (PHILLIPPE COURARD)** ប្រធានសភា

-អញ្ជើញចូលរួមប្រជុំជាមួយក្រុមមិត្តភាពទ្វេភាគីព្រឹទ្ធសភា-បារាំង ដើម្បីទទួលបបដិសណ្ឋារកិច្ច និងសវនាការការងារជាមួយប្រតិភូបារាំងដឹកនាំដោយ **ឯកឧត្តម Vincent Eble** សមាជិកព្រឹទ្ធសភាបារាំង និងជាប្រធានក្រុមមិត្តភាពទ្វេភាគីបារាំង-កម្ពុជា

-អញ្ជើញចូលរួមប្រជុំដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំគណៈកម្មការនៃសភាប្រើប្រាស់ភាសាបារាំង (APF)

-អញ្ជើញចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី០៨ មីនា ខួបលើកទី១០៦ ឆ្នាំ២០១៧ ស្តីពីស្ត្រីដើម្បីសុខសន្តិភាព និងវឌ្ឍនភាព និងការតាំងពិព័រណ៍ផលិតផល

ស្នាដៃ នៅខេត្តពោធិ៍សាត់

-អញ្ជើញចូលរួមជាអធិបតី ក្នុងអង្គសន្និបាតបូកសរុបលទ្ធផលការងារសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តពោធិ៍សាត់ ប្រចាំឆ្នាំ២០១៦ និងទិសដៅសម្រាប់អនុវត្តបន្តឆ្នាំ២០១៧

-អញ្ជើញធ្វើបទបង្ហាញស្តីពីតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនដល់សមាជិក-សមាជិកាក្រុមប្រឹក្សាឃុំ និងថ្នាក់ដឹកនាំភូមិសរុបចំនួន៤៥នាក់ មកពីឃុំព្រៃទឹង ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង ដែលបានអញ្ជើញមកទស្សនកិច្ច និងស្វែងយល់អំពីព្រឹទ្ធសភា

-អញ្ជើញចូលរួមប្រជុំពិភាក្សាពី ការត្រៀមលក្ខណៈសម្បត្តិឆ្ពោះទៅកាន់មហាសន្និបាតសហភាពអន្តរសភា លើកទី១៣៦ នៅទីក្រុងដាកា ប្រទេសបង់ក្លាដេស

-អញ្ជើញក្នុងពិធីធ្វើបទបង្ហាញអំពីគំរូប្លង់លំនៅដ្ឋានមានតម្លៃសមរម្យ សម្រាប់ប្រជាសហគមន៍ក្រីក្រនៅផ្ទះឬស្សីនៃអង្គការមូលនិធិអភិវឌ្ឍសហគមន៍ (CDF)

-អញ្ជើញចូលជួបសម្តែងការគួរសមជាមួយ **ឯកឧត្តម** Nuttavudh PHOTISARO ឯកអគ្គរាជទូតថៃ ប្រចាំនៅកម្ពុជាអំពីការត្រៀមទៅទស្សនកិច្ចរបស់ក្រុមមិត្តភាពសភានៃព្រះរាជាណាចក្រកម្ពុជា ទៅព្រះរាជាណាចក្រថៃឡង់ដ៍

-អញ្ជើញអមដំណើរគណៈប្រតិភូព្រឹទ្ធសភាបារាំងនៃសាធារណរដ្ឋបារាំង ទៅទស្សនកិច្ចប្រាសាទនៅខេត្តសៀមរាប និងខេត្តព្រះវិហារ ព្រមទាំងទស្សនកិច្ចនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ ខេត្តពោធិ៍សាត់

-អញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី សេចក្តីព្រាងច្បាប់ប្រកាសស្តីពីការកំណត់កម្រៃបែបបទគយ ក្រៅការិយាល័យគយ

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្តាខេត្ត-រាជធានីទូទាំងប្រទេសចំនួន១៩៨លើក ដើម្បីចុះជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្សការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និង

ពិធីផ្សេងៗសរុបចំនួន៩៣លើក ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-អនុញ្ញាតឲ្យលោកស្រី Soomsok Boonyabancha អគ្គលេខាធិការអង្គការសម្ព័ន្ធភាពអាស៊ី ដើម្បីសិទ្ធិលំនៅដ្ឋាន (ACHR) ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារស្តីពី ការបន្តអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា ។/

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមេសា ឆ្នាំ២០១៧

**ជ.ប្រធានព្រឹទ្ធសភា**
**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ